# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៧ សសរ

# សេចក្តីសំរេច

## ស្តីពី

## ការកែសំរួលសេចក្តីសំរេច ស្តីពីការបង្កើតក្រុមការងារតាមវិស័យ សំរាប់ធ្វើជាដៃគូពិភាក្សាការងារជាមួយផ្នែកឯកជន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃ ទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- យោងអនុក្រឹត្យលេខ១៤៧ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសេចក្តីសំរេចលេខ៤៧ សសរ. ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៤ ស្តីពីការបង្កើតក្រុមការងារតាមវិស័យសំរាប់ធ្វើជាដៃគូពិភាក្សាការងារជាមួយផ្នែកឯកជន
- យោងសេចក្តីជូនដំណឹងលេខ ១១៦៩ សជណ ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៦ ស្តីពីលទ្ធផលនៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជនលើកទី១០ នាថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០៦
- អនុលោមតាមតំរូវការចាំបាច់នៃការងារ

## សម្រេច

**ប្រការ១:** កែសម្រួល ដោយបន្ថែមក្រុមការងារតំណាងភាគីរាជរដ្ឋាភិបាល ក្នុងប្រការ១នៃសេចក្តីសម្រេចលេខ៤៧ សសរ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៤ ស្តីពីការបង្កើតក្រុមការងារតាមវិស័យ សំរាប់ធ្វើជាដៃគូពិភាក្សាការងារ ជាមួយផ្នែកឯកជន ដូចខាងក្រោម :

៩. **ក្រុមការងារផ្នែកទំនាក់ទំនងវិជ្ជាជីវៈ**

| | | | |
|---|---|---|---|
| ១- ឯកឧត្តម **អ៊ិត សំហេង** | រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ប្រធាន |
| ២- ឯកឧត្តម **វង សូត** | រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធាន |
| ៣- ឯកឧត្តម **សុខ ចិន្តា** | អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៤- ឯកឧត្តម **សេង លឹមនៅ** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៥- ឯកឧត្តម **ម៉ុន សម** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៦- ឯកឧត្តម **ម៉ៅ ថូរ៉ា** | អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៧- លោកជំទាវ **ចាន់ សុន្ធារី** | អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| ៨- ឯកឧត្តម **អ៊ុំ មាន** | អនុរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ៩- ឯកឧត្តម **ឌុច សុវណ្ណារី** | អនុរដ្ឋលេខាធិការក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | សមាជិក |
| ១០- ឯកឧត្តម **សាត សាមី** | អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ១១- ឯកឧត្តម **ស៊ឹម សួង** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ១២- ឯកឧត្តម **ឃួន រ៉ានីន** | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ១៣- ឯកឧត្តម **ថៃ សុខខេង** | អគ្គលេខាធិការរងក្រុមប្រឹក្សាអ្នកច្បាប់ | សមាជិក |
| ១៤- ឯកឧត្តម **ឆយ អួន** | សមាជិកក្រុមសង្កេតការសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១៥- លោកជំទាវ **ជូ បុនអេង** | អគ្គនាយកបច្ចេកទេសក្រសួងកិច្ចការនារី | សមាជិក |
| ១៦- លោក **ប្រាក់ ថាវរមិជា** | អគ្គនាយករងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១៧- ឧត្តមសេនីយឯក **គន្ធ សំអឿន** | ប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ អគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រសួងមហាផ្ទៃ) | សមាជិក |

**ប្រការ២:** ក្រៅពីភារកិច្ចដែលមានចែងក្នុងប្រការ២ និងប្រការ៣ នៃសេចក្តីសំរេចលេខ៤៧ សសរ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៤ ក្រុមការងារផ្នែកទំនាក់ទំនងវិជ្ជាជីវៈនេះ មានភារកិច្ចសំខាន់ៗ ដូចខាងក្រោម :

១- ពិនិត្យដោះស្រាយការទាមទាររបស់កម្មករ-និយោជិត និងនិយោជក ដោយឈរលើមូលដ្ឋានច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។

២- ទំនាក់ទំនងសំរបសំរួលរៀបចំបង្កើតក្រុមការងារផ្នែកឯកជន ដែលជាដៃគូពិភាក្សាជាមួយខ្លួន ស្រប តាមខ្លឹមសារចំណុចទី៦ នៃសេចក្តីជូនដំណឹងលេខ ១១៦៩ សជណ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៦។

៣- សហការជាមួយដៃគូផ្នែកឯកជន ក្នុងការរៀបចំយន្តការអចិន្ត្រៃយ៍ ដែលមានចរិតជាការចងចង្អោម បណ្តារោងចក្រ សំរាប់ជាសេនាធិការបំរើអោយក្រុមការងារ ក្នុងការលើកឡើងនូវវិធានការដោះ ស្រាយអោយបានទាន់ពេលវេលា ដើម្បីទប់ស្កាត់រាល់បាតុភាពអសកម្មជាយថាហេតុ។

៤- សហការពិនិត្យ និងសំរបសំរួលជាមួយផ្នែកឯកជន ក្នុងក្របខ័ណ្ឌច្បាប់-បទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ដើម្បីកំណត់អោយបានច្បាស់លាស់រវាងការងារវេនយប់ និងការងារបន្ថែមម៉ោង សំដៅបង្កើនការងារ ផង ធានាផលិតកម្មអោយដំណើរការរលូនផង និងពង្រីកការអនុវត្តនីតិរដ្ឋានពលកម្មនៅកម្ពុជាផង។

៥- ផ្តួចផ្តើមគំនិតក្នុងការរៀបចំគោលនយោបាយ និងបំពេញភារកិច្ចចាំបាច់ផ្សេងៗទៀត ដែលមាន ប្រយោជន៍ដល់គ្រប់ភាគីពាក់ព័ន្ធក្នុងក្របខ័ណ្ឌការងារ។

**ប្រការ៣:** លុបចេញនូវពាក្យ "*សហរដ្ឋមន្ត្រី*" ក្នុងប្រការ៨ នៃសេចក្តីសំរេចលេខ៤៧ សសរ ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៤ ស្តីពីការបង្កើតក្រុមការងារតាមវិស័យ សំរាប់ធ្វើជាដៃគូពិភាក្សាការងារជាមួយផ្នែកឯកជន ។

**ប្រការ៤:** ក្រៅពីការកែសំរួលដូចមានក្នុងប្រការ១ និងប្រការ៣ខាងលើ ខ្លឹមសារផ្សេងៗទៀត នៃសេចក្តីសំរេចលេខ ៤៧សសរ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៤ ស្តីពីការបង្កើតក្រុមការងារតាមវិស័យ សំរាប់ធ្វើជាដៃគូ ពិភាក្សាការងារជាមួយផ្នែកឯកជន នៅមានសុពលភាពអនុវត្តដដែល។

**ប្រការ៥ :** ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា -រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី -រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ -រដ្ឋមន្ត្រីគ្រប់ក្រសួង -អភិបាលគ្រប់ខេត្ត/ក្រុង-គ្រប់ប្រធានស្ថាប័ន/ អង្គភាពដែលពាក់ព័ន្ធ និងសមាសភាពដូចមានចែងក្នុងប្រការ១ ត្រូវទទួលអនុវត្តសេចក្តីសំរេចនេះ អោយ មានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ប្រធាន "ក.អ.ក"
- ដូចប្រការ ៥ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ